EXT/RGC-97

# សេចក្តីណែនាំ

ស្តីពី

MOSALVY

ការគាំពារ [illegible] សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និង

យុវនីតិសម្បទា ជូនក្រុមប្រឹក្សាឃុំ-សង្កាត់

361 GUI

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខៈ០០៣ សកបយ.សណន

បណ្ណាល័យ
គ.ជ.អ.ប

# សេចក្តីណែនាំ

## ស្តីពី

## ការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់

ក្នុងគោលបំណង ដើម្បីអនុវត្តការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ឱ្យកាន់តែល្អប្រសើរ ស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ ដោយយោង:

-អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា

-ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង

-ច្បាប់ស្តីពីការកែទម្រង់រដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់

-ប្រកាសណែនាំអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការអភិវឌ្ឍន៍ឃុំ-សង្កាត់

-សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ ស្តីពីគោលការណ៍ សំរាប់ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីគាំទ្រការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ តាមបែបវិមជ្ឈការ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងដូចខាងក្រោម:

library.ncdd.gov.kh
002736

*ក. តួនាទី និងភារកិច្ចរបស់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង:*

-ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចទទួលខុសត្រូវរបស់វិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឱ្យដល់ការិយាល័យខណ្ឌ-ស្រុក សំដៅបញ្ជ្រាប ការងារនេះទៅក្នុងកម្មវិធីសិលា។

-សហការជាមួយ គណៈកម្មការអភិវឌ្ឍន៍ខេត្ត-ក្រុង និងមន្ទីរផែនការខេត្ត-ក្រុងរៀបចំផែនការការងារវិស័យរបស់ខ្លួន ឆ្លើយតបទៅនឹងចំណុចអាទិភាព ក្នុងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់។

-សហការជាមួយគណៈកម្មាធិការប្រតិបត្តិខេត្ត ដើម្បីស្នើសុំកញ្ចប់ថវិកា សំរាប់អភិវឌ្ឍន៍វិស័យរបស់ខ្លួន ។

-ធ្វើការកែតំរូវ និងផ្តល់អនុសាសន៍ ដល់មូលដ្ឋានចំពោះការងារអភិវឌ្ឍន៍ វិស័យសង្គមកិច្ច និងការងារ។

-រៀបចំបណ្តាញភ្ជាក់ងារថ្នាក់ខេត្ត ក្រុង ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ដើម្បីក្តាប់បានស្ថានភាពជាក់ស្តែង របស់មូលដ្ឋាន ។

-ការណែនាំលំអិតដូចមានចែងក្នុងឧបសម្ព័ន្ធ ស្តីពីការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-សហការជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងការផ្តល់សេវាដល់ការគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-តាមដាន ត្រួតពិនិត្យ វាយតំលៃ និងការកែតំរូវ ។

-ផ្តល់របាយការណ៍ ស្តីពីសកម្មភាពការងារជាទៀងទាត់ មកថ្នាក់ក្រសួង។

*ខ. តួនាទី និងភារកិច្ចរបស់ការិយាល័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាស្រុក-ខណ្ឌ:*

-ណែនាំដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពីរបៀបប្រមូលទិន្នន័យ លើការងារសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

-ប្រមូលពត៌មានស្តីពីស្ថានភាពប្រជាជន ដែលងាយទទួលរងគ្រោះក្នុងស្រុក ខណ្ឌរួមមានគ្រួសារដែលស្ថិតក្នុងស្ថានភាពជីវភាពលំបាក ជនអនាថា ក្មេងអនាថា យុវជនដែលប្រព្រឹត្តអំពើអបាយមុខ ជនចាស់ជរាគ្មានទីពឹង កុមារកំព្រា ស្ត្រីពេស្យា ជនពិការ ។ល។

-ប្រមូលពត៌មានស្តីពីទីផ្សារការងារ និងបញ្ហាគ្មានការងារធ្វើ ផ្សព្វផ្សាយពត៌មានជូនអ្នកគ្មានការងារធ្វើ សិក្សាពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឱ្យសមស្របទៅនឹងទីផ្សារការងារទៅក្នុងមូលដ្ឋាន។

-សហការជាមួយគណៈកម្មការអភិវឌ្ឍន៍ស្រុក ខណ្ឌ និងការិយាល័យពាក់ព័ន្ធ ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពី ការងារសង្គមកិច្ច ការងារបណ្តុះ បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-សហការជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងការផ្តល់សេវាដល់ការគាំទ្រ ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-ផ្សព្វផ្សាយគោលការណ៍ណែនាំ ពីថ្នាក់ជាតិ និងខេត្ត-ក្រុង ដល់ក្រុមប្រឹក្សា ឃុំ-សង្កាត់ ។

-រៀបចំសេចក្តីព្រាងផែនការស្តីពីការអភិវឌ្ឍន៍វិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅក្នុងស្រុកខណ្ឌរបស់ខ្លួន ផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ទាំង ១១ ជំហាន។

- សហការជាមួយក្រុមប្រឹក្សាឃុំ -សង្កាត់ ក្នុងការ :

  - មុខសញ្ញាជនងាយរងគ្រោះ
  - តម្រូវការជាក់ស្តែងរបស់មូលដ្ឋាន ស្តីពីការងារសង្គមកិច្ច
  - របៀបរៀបចំគំរោងផែនការអភិវឌ្ឍន៍វិស័យសង្គមកិច្ច និងការងារឃុំ-សង្កាត់ ( ១១ ជំហាន)

-តាមដាន ត្រួតពិនិត្យ វាយតំលៃ និងការកែតំរូវ

-ផ្តល់របាយការណ៍ ស្តីពីសកម្មភាពការងារជាទៀងទាត់ មកថ្នាក់ខេត្ត-ក្រុង។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្ឃឹមថា អស់លោក លោកស្រី ដែលជាអ្នកដឹកនាំ និងជាអ្នកអនុវត្តផ្ទាល់ក្នុងការងារខាងលើនេះ នៅតាមបណ្តាខេត្ត-ក្រុង នឹងទទួលបានជោគជ័យ ។

ភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

ឧបសម្ព័ន្ធ

## ការណែនាំលំអិត ស្តីពីការគាំទ្រ
## វិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា
## ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់

## *I-ស្ថានភាពរួម:*

### *ក-បរិបទនៃភាពក្រីក្រ:*

តាមតួលេខដែលបានបង្ហាញតាមរយៈការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ ១៩៩៨ ឃើញថា ប្រជាជន ៣៦% រស់ នៅក្រោមបន្ទាត់នៃភាពក្រីក្រ ហើយ ៨៥% រស់នៅជនបទ ។ ការលេចឡើងនៃទំនោរ ទៅរកការកើនឡើងនៃភាព បាត់បង់ដីធ្លី គឺជាសូចនាករមួយអាចជឿជាក់បាន អំពីទំនោរឆ្ពោះទៅរកភាពក្រីក្រជាទូទៅ ។ ភាពក្រីក្របណ្តាលមក ពីគ្មានឱកាសគ្រប់គ្រាន់ ក្នុងសកម្មភាពកសិកម្ម សេដ្ឋកិច្ច និង សកម្មភាពដទៃទៀតក្នុងតំបន់ជនបទ។ ការខ្វះឱកាសនេះ គឺដោយសារការច្របូកច្របល់នៃកត្តាជាច្រើន ប៉ុន្តែវាមានប្រសិទ្ធិភាពយ៉ាងខ្លាំងទៅលើសមត្ថភាព ដែលអាចអនុវត្តបានលទ្ធភាពដែលអាចទទួលយកបាន និងសមភាពនៃការផ្តល់សេវាសាធារណៈ ។

យើងមានគោលនយោបាយជាច្រើន ដែលបានសង្កត់ធ្ងន់ទៅលើបញ្ហាស្មុគ្រស្មាញទាំងអស់នេះ ។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺ ការកាត់បន្ថយភាពក្រីក្រ តាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាពក្នុងរយៈពេលវែង ដោយធានាបាននូវនិរន្តរភាពបរិស្ថាន និងសច្ចធម៌សង្គម។ ដូច្នេះផ្នែកដែលអាចពិចារណា លើកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយភាពក្រីក្រ គឺផ្តោតសំខាន់ទៅលើការបង្កើតនូវបរិបទដែលមានភាពងាយស្រួលសំរាប់កំណើនសេដ្ឋកិច្ច ។ ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច

និងវិស័យហិរញ្ញវត្ថុ ដែលល្អត្រឹមត្រូវមានលក្ខណៈសំខាន់ចាំបាច់ណាស់ ប៉ុន្តែទាំងអស់នេះមិនអាចធានាបាននូវការធ្វើឱ្យប្រសើរឡើង នូវជីវភាពរបស់ប្រជាជននៅជនបទដែលភាគច្រើនជាអ្នកក្រីក្រ ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានកំណត់នូវកត្តារាំងស្ទះនានា និងធ្វើការកំណត់កម្មវិធីគោលនយោបាយ ព្រមជាមួយទិសដៅដើម្បីធ្វើការបង្កើនប្រាក់ចំណូល ដល់ប្រជាជនដែលរស់នៅតំបន់ជនបទ ។ ការធ្វើឱ្យប្រសើរឡើងនូវផ្នែកទាំងអស់នេះ នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ក្នុងផ្នែកផ្សេងៗពីគ្នា តាមរយៈការធ្វើឱ្យប្រសើរឡើង នូវលទ្ធភាពប្រើប្រាស់សេវាជាមូលដ្ឋាន ។ ជីវភាពជនបទបានប្រសើរឡើង គឺអាស្រ័យទៅលើទំហំនៃភាពក្រីក្រមានការថយចុះ ។ សុខភាពទ្រុឌទ្រោម កង្វះការសិក្សា កង្វះហេដ្ឋារចនាសម្ព័ន្ធ និងផលិតភាពទាប ដែលជាហេតុធ្វើឱ្យ ប្រជាជននៅជនបទធ្លាក់ខ្លួនទៅក្នុងភាពក្រីក្រ ។

តាមការធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ១៩៩៨ មក កម្ពុជាបានធ្វើឱ្យមានការប្រែប្រួលយ៉ាងច្រើន ក្នុងការកាត់បន្ថយភាពក្រីក្រ ។ អត្រាប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ បានធ្លាក់ចុះពី ៤០%មកនៅត្រឹម ៣៦% ហើយ អត្រានេះនឹងធ្លាក់មកនៅត្រឹម ៣១%នៅឆ្នាំ ២០០៥ ខាងមុខនេះ។ ភាគច្រើននៃកំណើនសេដ្ឋកិច្ច គឺបានមកពីការវិនិយោគខាងវិស័យឧស្សាហកម្ម និងសេវាកម្ម ។ ទោះបីជាអត្រានៃប្រជាជន ដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រមានត្រឹមតែ ៣៦% ប៉ុន្តែអត្រានៃអ្នកដែលរស់នៅកៀកបំផុត ជាមួយនឹងខ្សែបន្ទាត់សន្តិសុខស្បៀង មានរហូតដល់ទៅ ២០% ។ ប្រជាជនទាំងអស់នោះ ភាគច្រើនជាអ្នកដែលរស់នៅតាមតំបន់ជនបទ និងមានមុខរបរជាកសិករ ។ អ្វីដែលគួរឱ្យកត់សំគាល់នោះគឺ ប្រជាកសិករយើងធ្វើស្រែទៅតាមបែបបទប្រពៃណី មិនទាន់ចាប់យកនូវអ្វីដែល ជាប្រពលវប្បកម្ម ឬបច្ចេកទេសកសិកម្មទាន់សម័យនៅឡើយ ។

ការខ្វះខាតជីវភាព បានជំរុញឱ្យពួកគេត្រូវចាកចេញពីទឹកដីកំណើត ទៅកាន់ទីក្រុង ទីប្រជុំជននានា ដើម្បីស្វែងរកការងារធ្វើបន្ថែមចំណូលក្នុងគ្រួសារ ដូចជាការធ្វើកម្មករតាមរោងចក្រ សហគ្រាស កម្មករសំណង់ កម្មករលីសែង រត់ស៊ីក្លូ រ៉ឺម៉ក ម៉ូតូឌុប ។ល។ ទៅតាមលទ្ធភាពដែលពួកគេអាចរកបាន ។ ដោយមូលហេតុមិនមានជំនាញច្បាស់លាស់ ឬមានជំនាញដែរ តែមិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ ធ្វើឱ្យពួកគេមួយចំនួន ត្រូវតែលតោលក្នុងទីក្រុង ទីប្រជុំជន គ្មានការងារធ្វើ ស្នាក់នៅដោយអនាធិបតេយ្យតាមដងផ្លូវទីសាធារណៈ និងអាចឈានទៅបង្កបាតុភាពអសកម្មក្នុងសង្គមថែមទៀតផង ។ ពួកគេទាំងនោះមានគ្រប់សមាសភាពគ្រប់វ័យ គ្រប់ភេទ រស់នៅលាយឡំគ្នា និងមានទាំងបង្កើតជាក្រុមជាពួក ដើម្បីធ្វើសកម្មភាពដូចជាដើរសុំទាន លួច ឆក់ ប្លន់ ប្រព្រឹត្តិអំពើអនាចារ ពេស្យាចារ សេពគ្រឿងញៀន និងឈានទៅដល់ប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មថែមទៀតផង ។

សង្គ្រាម និងភាពក្រីក្របានបន្សល់ទុកឱ្យមនុស្សជាច្រើននាក់ ត្រូវរស់នៅក្នុងភាពលំបាកវេទនា និងភាពអត់ឃ្លាន ។ ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ សន្តិភាពដ៏ពេញលេញត្រូវបានផ្តល់ឱ្យកម្ពុជានៅគ្រប់ទីកន្លែង ប៉ុន្តែបញ្ហាដែលចោទមានឡើងនៅកម្ពុជា គឺភាពក្រីក្រក្នុងជួរប្រជាជន ជាពិសេសប្រជាជនដែលរស់នៅតាមជនបទដែលមានប្រមាណ ៨៤.៣ ភាគរយ ។

ស្ថិតក្នុងស្ថានភាពនៃបរិបទខាងលើ ក្រសួងបានរៀបចំក្របខណ្ឌយុទ្ធសាស្រ្តការងារ ក្នុងការអនុវត្តន៍កម្មវិធីការងារសាកល្បង លើវិស័យសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីគាំទ្រដល់ក្រុមប្រឹក្សា ឃុំ-សង្កាត់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ពោលគឺការបញ្ជ្រាបការងារសង្គមកិច្ច

ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយអនុលោមតាមប្រព័ន្ធ វិមជ្ឈការ និងវិសហមជ្ឈការ ដោយសហការជាមួយកម្មវិធី សិលា ។

*II-បេសកកម្មរូមៈ*

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងរាល់សកម្មភាពទាំងអស់ ដែលទាក់ទងទៅនឹងវិស័យសង្គមកិច្ច វិស័យការងារ វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិស័យយុវនីតិសម្បទា។ គិតមកដល់ចុងឆ្នាំ ២០០២ នេះក្រសួងមានមន្ត្រីរាជការសរុបចំនួនៈ ១.៧១១ នាក់ក្នុងនោះ រដ្ឋបាលកណ្តាល ៦៤៨ នាក់ រដ្ឋបាលមូលដ្ឋាន ១.០៦៣ នាក់ និងមានមន្ត្រីជាប់កិច្ចសន្យាចំនួន ៤២៣ នាក់ ។

*១-តួនាទី និងភារកិច្ចទទួលខុសត្រូវៈ*

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានតួនាទី និងភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោមៈ

*ក-វិស័យសង្គមកិច្ចៈ*

-សំរបសំរួល និងគ្រប់គ្រងរាល់សេវាកម្មសង្គមកិច្ចរបស់រដ្ឋ សំរាប់ជួយប្រជាពលរដ្ឋ កាត់បន្ថយគ្រោះភ័យផ្សេងៗ និងរៀបចំសកម្មភាពសង្គម ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ ជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ កុមារអនាថារស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា ជនអនាថារស់នៅតាមចិញ្ចើមថ្នល់ កុមារញៀន គ្រឿងញៀន ស្ត្រីពេស្យា ជនដែលមានមេរោគអេដស៍ ។ល។

-ជួយដល់ក្រុមជនដែលមានជួបការលំបាកជាងគេក្នុងសង្គម ។

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ចាត់វិធានការតាមផ្លូវច្បាប់ ក្នុងការពិនិត្យ និងទប់ស្កាត់អំពើ ពេស្យាចារ និងការជួញដូរមនុស្ស ។

-ជួយដល់ជនរងគ្រោះ ដោយភ័យន្តរាយផ្សេងៗ ដូចជាគ្រោះធម្មជាតិ សង្គ្រាម និងគ្រោះថ្នាក់ផ្សេងៗទៀត ។

-ទំនុកបំរុង និងថែរក្សាការពារ អប់រំកុមារកំព្រាគ្រប់ប្រភេទ ។

-ការពារកុមារ ដែលត្រូវគេរំលោភបំពានតាមផ្លូវភេទ និងប្រភេទនៃការជួញដូរ និងការកេងប្រវ័ញ្ចតាមគ្រប់រូបភាព ។

-រៀបចំគោលនយោបាយគាំពារជនពិការ និងសំរបសំរួលការងារស្តារលទ្ធភាពពលកម្មរូបរាងកាយ និងផ្តល់ជំនាញវិជ្ជាជីវៈដល់ជនពិការគ្រប់ប្រភេទ ។

-គ្រប់គ្រងរបបសោធននិវត្តន៍ សំរាប់មន្ត្រីរាជការតាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

-គ្រប់គ្រងរបបធានារ៉ាប់រងសង្គម ដល់កូនកំព្រាពីសពមន្ត្រីរាជការ ។

***ខ-ទិស័យការងារ:***

អនុវត្តច្បាប់ស្តីពីការងារ សំដៅធានាការកែលំអអនាម័យ សុខភាព សន្តិសុខ និងលក្ខខណ្ឌស្តីពីការងារ នៅតាម រោងចក្រ សហគ្រាស ។

-ធ្វើអធិការកិច្ចការងារ តាមរោងចក្រ សហគ្រាស តាមកាលកំណត់នៃបញ្ញត្តិ ស្តីពីរដ្ឋបាលការងារ ។

-តាមដានការអនុវត្តន៍ច្បាប់ការងារ

និងបទបញ្ញត្តិពាក់ព័ន្ធទៅនឹងបទដ្ឋានការងារ លក្ខខណ្ឌការងារ សន្តិសុខការងារ និងការការពារសុខភាព កម្មករ និយោជិត ។

-ជួយការពារ សំរបសំរួល និងទំនាក់ទំនង រវាងបណ្តាអង្គការតំណាងកម្មករ និយោជិត និងសមាគមនិយោជក នៅក្នុងរោងចក្រ សហគ្រាស ។

-ដោះស្រាយវិវាទការងារ ជាបុគ្គល និងជារួមតាមនីតិវិធីដោយឈរលើស្មារតីច្បាប់ ។

-សិក្សា និងរៀបចំគោលនយោបាយជាតិសំរាប់មុខរបរ ដើម្បីរកតំរូវការទីផ្សារការងារ សរុបចំនួននៃអ្នកគ្មានការងារធ្វើ និងអ្នកមានការងារធ្វើមិនពេញលេញក្នុងទូទាំងប្រទេស ។

-គ្រប់គ្រងការប្រើប្រាស់ពលកម្ម នៃជនកម្ពុជាក្នុង និងក្រៅប្រទេស ។

-រៀបចំសេវាសន្តិសុខសង្គម

សំរាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិ នៃច្បាប់ស្តីពីការងារ និងគ្រប់ គ្រងបេឡាជាតិ ស្តីពីរបបសន្តិសុខសង្គម ។

***គ-វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ***

-អភិវឌ្ឍន៍គោលនយោបាយជាតិ សំរាប់មុខរបរ ដោយឈរលើនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ជួយអភិវឌ្ឍន៍មុខជំនាញ និងមានទិសដៅជួយពលរដ្ឋដែលជួបការលំបាកជាងគេ ឱ្យមានមុខរបរសមស្រប និងជួយសហគ្រាសគ្រឹះស្ថាន ឱ្យរកបានហត្ថពលករប្រកបដោយគុណភាព ។

-រៀបចំ និងគ្រប់គ្រងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលផ្សារភ្ជាប់ទៅនឹងតំរូវការទីផ្សារការងារ ។

-សហការ និងសំរបសំរួលជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍន៍វិស័យបណ្តុះ បណ្តាលវិជ្ជាជីវៈ ។

-សហការជាមួយរោងចក្រ សហគ្រាស ដើម្បីលើកកំពស់អភិវឌ្ឍន៍មុខជំនាញ ។

-គ្រប់គ្រងការហ្វឹកហ្វឺនកូនជាង និងបេឡានៃការហ្វឹកហ្វឺនកូនជាង ទៅតាមច្បាប់ស្តីពីការងារ ។

***ឃ-វិស័យយុវនីតិសម្បទា:***

-គ្រប់គ្រងក្មេងពីអាយុ ៧ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ដែលបានប្រព្រឹត្តិបទល្មើស ពាលា អនាថា សេពគ្រឿងញៀន និងផ្តល់កម្មវិធីស្តារលទ្ធភាព ដើម្បីប្រែក្លាយពួកគេឱ្យទៅជាពលរដ្ឋល្អ ។

-បង្កើតមណ្ឌលស្តារលទ្ធភាព ដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តិ អំពើខុសឆ្គង មកគ្រប់គ្រងអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ។

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីកសាងកម្មវិធីបណ្តុះបណ្តាល និងស្តារលទ្ធភាព សំរាប់កុមារប្រព្រឹត្តិបទល្មើស ។

-កសាងគោលការណ៍ច្បាប់ គោលនយោបាយ និងបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា

***២-បញ្ហាប្រឈម:***

តាមរយៈនៃការចុះសិក្សាស្រាវជ្រាវ និងស្វែងយល់ពីសកម្មភាពនៃការអនុវត្តន៍កម្មវិធីសិលានៅតាមខេត្ត-ក្រុងមួយចំនួនកន្លងមក យើងពិនិត្យឃើញថាមានបញ្ហាប្រឈមមួយចំនួនដែលបានកើតមាននៅតាមមូលដ្ឋាននៃខេត្ត-ក្រុងទាំងនោះជាអាទិ៍:

-វិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានវិសាលភាពធំធេង ។

-ក្រសួងមិនទាន់មានគោលការណ៍ណែនាំច្បាស់លាស់ ពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ស្តីពីការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-ការផ្សព្វផ្សាយស្តីពីតួនាទី ភារកិច្ចទទួលខុសត្រូវ និងពតិមានផ្សេងៗ លើវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មិនបានជ្រួតជ្រាបទូលំទូលាយដល់មូលដ្ឋាន ។

-សមត្ថភាពមន្ត្រីនៅមូលដ្ឋាននៅមានកំរិត ។

-ការសហការរវាងមន្ទីរ សកបយ ខេត្ត-ក្រុង ការិយាល័យ សកបយ ខណ្ឌ-ស្រុកនិងគណៈកម្មការអភិវឌ្ឍន៍ខេត្ត-ក្រុង មិនទាន់បានស៊ីសង្វាក់នៅឡើយ ។

-ក្រសួងមិនមានរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ឃុំ-សង្កត់ ។

-មិនបានបញ្ចូលការងារសង្គមកិច្ចទៅក្នុងផែនការអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-ប្រព័ន្ធទំនាក់ទំនងនៅមូលដ្ឋាននៅមានកំរិត ។

-ការយល់ដឹងពីវិស័យសង្គមកិច្ច របស់ប្រជាពលរដ្ឋនៅមូលដ្ឋាននៅមានកំរិតទាប ។

### ៣. ទស្សនវិស័យ:

ទស្សនៈវិស័យនៃការបញ្ជ្រាបការងារសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ នឹងត្រូវកំណត់

ដោយកត្តាសំខាន់ៗ ជាសារវ័ន្តជាអាទិ៍ៈ លទ្ធភាពនៃការគៀងគរធនធាន ប្រសិទ្ធិភាព តម្លាភាព និងសមត្ថភាពចាត់ចែងការងារជាក់ស្តែងរបស់មូលដ្ឋាន ។ យើងរំពឹងថា ការបញ្ជ្រាបការងារ សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាការរួមចំណែកយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈនៃការបង្កើតប្រព័ន្ធអភិបាលកិច្ចល្អ តាមបែបចូលរួម ដើម្បីផ្តល់សេវាគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ប្រកបដោយប្រសិទ្ធិភាព ហើយរក្សាបាននូវនិរន្តភាពក្នុងភាពជាដៃគូ រវាងរាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ។

### ៤.គោលបំណង:

ស្ថិតក្នុងទិសដៅលើកកំពស់ ការគាំទ្រវិស័យសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្នុងការអនុវត្តន៍សាកល្បងនូវប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការដោយសហការជាមួយ កម្មវិធីសិលា ដើម្បីរួមចំណែក ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ចាំបាច់ត្រូវធ្វើការទប់ស្កាត់ និងផ្តល់សេវាគាំ ទ្រនូវសកម្មភាពជាអាទិ៍ :

-ផ្តល់សេវាគាំទ្រដល់ជនចាស់ជរាគ្មានទីពឹង ជនពិការ កុមារកំព្រា កុមារអនាថា កុមារញៀន គ្រឿងញៀន កុមារយុវកុមារប្រព្រឹត្តបទល្មើសពាលាអនាចារ ។

-ផ្តល់សេវាគាំទ្រដល់ជនអនាថារស់នៅតាមចិញ្ចើមថ្នល់ ស្ត្រីពេស្យា ជនដែលមានមេរោគអេដស៍ និងទប់ស្កាត់ ការជួញដូរមនុស្ស ដោយធ្វើការទប់ស្កាត់នៅតាមមូលដ្ឋាន។

-ការពារកុមារដែលត្រូវគេរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

-អប់រំ និងទប់ស្កាត់ការប្រើអំពើហឹង្សាក្នុងគ្រួសារ ជាពិសេសនៅតាមជនបទ ។

-លើកកំពស់សុខុមាលភាពប្រជាពលរដ្ឋ នៅតាមជនបទ ដោយធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ និង អង្គការនានា ។

-លើកកំពស់សមភាពយែនឌ័រនៅក្នុងសង្គម ជាពិសេសនៅតាមជនបទ

-ជួយដល់ជនរងគ្រោះ ដោយភ័យន្តរាយផ្សេងៗ ដោយគ្រោះធម្មជាតិ សង្គ្រាម និងគ្រោះថ្នាក់ផ្សេងៗ ។

-ដោះស្រាយវិវាទការងារ

-ផ្តល់ជំនាញវិជ្ជាជីវៈ ដើម្បីបង្កើនមុខរបរ និងដោះស្រាយការងារធ្វើ សមស្របទៅនឹងស្ថានភាពជាក់ស្តែង និង តម្រូវការនៃទីផ្សារការងារ ។

ផ្អែកតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០១ ក្នុងមាត្រាទី ៤០ ដែលបានចែងច្បាស់អំពីតួនាទី ភារកិច្ចរបស់ជំទប់ទី ២ (ចៅសង្កាត់រងទី២) លើការងារសង្គមកិច្ច ដើម្បីគាំទ្រដល់ក្រុម ប្រឹក្សាឃុំ-សង្កាត់ និងផ្អែកតាមទស្សនៈវិស័យខាងលើ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា គ្រប់ខេត្ត-ក្រុង ត្រូវសហការអនុវត្តនូវតួនាទី និងភារកិច្ចមួយចំនួន ដូចបានរៀបរាប់នៅក្នុងផ្នែកទី៣ៈ

*III- ការណែនាំ ការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាដល់ក្រុមប្រឹក្សា ឃុំ-សង្កាត់ៈ*

*១-ការចូលរួមរបស់កម្លាំងមូលដ្ឋានៈ*

ដើម្បីសំរេចបាននូវការអនុវត្តន៍ សេចក្តីណែនាំក្នុងការបញ្ជ្រាបការងារ សង្គមកិច្ច និងដើម្បីអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់ ទាមទារឱ្យមានការសហការ ជាមួយស្ថាប័នពាក់ព័ន្ធ និងមានការគាំទ្រពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផ្ទាល់:

-មានការគាំទ្រពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន

-មានទុនបដិភាគ សំរាប់ចូលរួមអនុវត្តគំរោងកម្មវិធី

-មន្ទីរ សកបយ ខេត្ត-ក្រុង និងការិយាល័យខណ្ឌ-ស្រុក សហការជាមួយ កម្មវិធីសិលា និងមន្ត្រីសំរបសំរួល ថ្នាក់ខេត្ត-ស្រុករបស់ខ្លួន ដើម្បីអនុវត្តការ គាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពីការបញ្ជ្រាបការងារ សង្គមកិច្ច ទៅ ក្នុងផែនការសកម្មភាពអភិវឌ្ឍន៍ឃុំ សង្កាត់ ។

### ២. ក្របខណ្ឌការងារ និងតួនាទីអនុវត្ត:

ដើម្បីធានាការរៀបចំគ្រប់គ្រងគាំទ្រដល់វិស័យសង្គមកិច្ច ការងារ បណ្តុះ បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សំរាប់ចូលរួមចំណែកពង្រឹងសមត្ថភាព អាជ្ញាធរ មូលដ្ឋាន និងជាផ្នែកអនុវត្តមួយនូវគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។ វិធីសាស្ត្រក្នុងការអនុវត្តន៍សាកល្បង សេចក្តីណែនាំស្តីពីការគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ទាម ទារឱ្យមានការសំរបសំរួលគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យមានការពិភាក្សា និងព្រមព្រៀង ជាមួយភាគីពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីណែនាំនេះ ។

#### ក. តួនាទី និងភារៈកិច្ចរបស់មន្ទីរ សកបយខេត្ត-ក្រុង:

-ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចទទួលខុសត្រូវរបស់វិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឱ្យដល់ការិយាល័យខណ្ឌ-ស្រុក សំដៅបញ្ជ្រាប ការងារនេះទៅក្នុងកម្មវិធីសីលា ។

-សហការជាមួយ គណៈកម្មការអភិវឌ្ឍន៍ខេត្តនិងមន្ទីរផែនការខេត្ត រៀបចំផែនការការងារវិស័យរបស់ខ្លួន ឆ្លើយតបទៅនឹងចំណុចអាទិភាព ក្នុងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-សហការជាមួយគណៈកម្មាធិការប្រតិបត្តិខេត្ត ដើម្បីស្នើសុំកញ្ចប់ថវិកា សំរាប់អភិវឌ្ឍន៍វិស័យរបស់ខ្លួន ។

-ធ្វើការកែតំរូវ និងផ្តល់អនុសាសន៍ ដល់មូលដ្ឋានចំពោះការងារអភិវឌ្ឍន៍វិយសង្គមកិច្ច។

-រៀបចំបណ្តាញភ្នាក់ងារថ្នាក់ខេត្ត ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ។

-សហការជាមួយអង្គការជាតិ និងអន្តរជាតិក្នុងការផ្តល់សេវាដល់ការគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-តាមដាន ត្រួតពិនិត្យ វាយតំលៃ និងការកែតំរូវ

-ផ្តល់របាយការណ៍ ស្តីពីសកម្មភាពការងារជាទៀងទាត់ មកថ្នាក់ក្រសួង។

***ខ_តួនាទី និងភារកិច្ចរបស់ការិយាល័យ សកបយស្រុកៈ***

-ណែនាំដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ស្តីពីរបៀបប្រមូលទិន្នន័យ លើការងារសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

-ប្រមូលពតិមានស្តីពីស្ថានភាពប្រជាជន ដែលងាយទទួលរងគ្រោះក្នុងស្រុកខណ្ឌ រួមមានគ្រួសារដែលស្ថិតក្នុង ស្ថានភាពជីវភាពលំបាក ជនអនាថាក្មេងអនាថា យុវជនដែលប្រព្រឹត្តិអំពើអបាយមុខ ជនចាស់ជរាគ្មានទីពឹងកុមារកំព្រា ស្ត្រីពេស្យា ជនពិការ ។ល។

-សហការជាមួយអង្គការជាតិ និងអន្តរជាតិ ក្នុងការផ្តល់សេវាដល់ការគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-ផ្សព្វផ្សាយគោលការណ៍ណែនាំ ពីថ្នាក់ជាតិ និងខេត្ត-ក្រុង ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-ប្រមូលពត៌មានស្តីពីទីផ្សារការងារ និងបញ្ហាគ្មានការងារធ្វើ ផ្សព្វផ្សាយពត៌មានជូនអ្នកគ្មានការងារធ្វើ សិក្សាពីតម្រូវការនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឱ្យសមស្របទៅនឹងទីផ្សារការងារនៅក្នុងមូលដ្ឋាន ។

-សហការជាមួយគណៈកម្មការអភិវឌ្ឍន៍ស្រុក និងការិយាល័យពាក់ព័ន្ធ ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការងារសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

-រៀបចំសេចក្តីព្រាងផែនការការងារ សំរាប់ផ្តល់សេវាគាំទ្រវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅក្នុងស្រុកខណ្ឌរបស់ខ្លួន ផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

-សហការជាមួយក្រុមប្រឹក្សាឃុំ -សង្កាត់ ក្នុងការ :

- ស្រង់ស្ថិតិមុខសញ្ញាជនងាយរងគ្រោះ
- សិក្សាពីតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន ស្តីពីការងារសង្គមកិច្ច
- រៀបចំគំរោងផែនការអភិវឌ្ឍន៍វិស័យសង្គមកិច្ចឃុំ-សង្កាត់

-តាមដាន ត្រួតពិនិត្យ វាយតំលៃ និងការកែតំរូវលើការងារសង្គមកិច្ច

-ផ្តល់របាយការណ៍ ស្តីពីសកម្មភាពការងារជាទៀងទាត់ មកថ្នាក់ខេត្ត-ក្រុង ។

## *IV- លទ្ធផលរំពឹងទុកៈ*

ផ្អែកតាមការអនុវត្តន៍គោលការណ៍ខាងលើ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រំពឹងថា នឹងទទួលបាននូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

-ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាជននៅតាមមូលដ្ឋាននឹងយល់ជ្រួតជ្រាបអំពីវិស័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

-ធានាបាននិរន្តភាពក្នុងការសហការរវាង ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ស្ថាប័នពាក់ព័ន្ធ ។

-រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

-ពង្រឹង និងពង្រីកសេវាសង្គមកិច្ច ឱ្យកាន់តែប្រសើរឡើងនៅថ្នាក់មូលដ្ឋាន

-កាត់បន្ថយអត្រាគ្មានការងារធ្វើ ឱ្យបានជាអតិបរមា ។

-មុខសញ្ញាជនដែលងាយទទួលរងគ្រោះក្នុងសង្គម បានទទួលនូវសេវាគាំទ្រ

-សុខុមាលភាពប្រជាជននៅតាមមូលដ្ឋាន ត្រូវបានលើកកំពស់

-ប្រជាជននឹងមានជំនាញវិជ្ជាជីវៈក្នុងការបង្កើនមុខរបរ សមស្របទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាន ។

## *V-សកម្មភាព៖*

### *១‑ផែនការការងារ៖*

| ល.រ | សកម្មភាព | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្នាក់ជាតិ | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | រៀបចំកសាងសេចក្តីណែនាំ និងលិខិតបទដ្ឋាននានា | ■ | ■ | ■ | | | | | | | | | |
| ២ | ផ្សព្វផ្សាយសេចក្តីណែនាំ និងលិខិតបទដ្ឋាននានា | ■ | ■ | ■ | | | | | | | | | |
| ៣ | តាមដានត្រួតពិនិត្យ វាយតំលៃ និងកែតម្រូវ | | | | | | | | | | | | ■ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ថ្នាក់ខេត្ត** | | | | | | | | | | | | | |
| ១ | ផ្សព្វផ្សាយបន្តនូវសេចក្ដីណែនាំ និងលិខិតបទដ្ឋាននានា | | | | | | | | | | | | |
| ២ | សំរបសំរួល និងតាមដានការអនុវត្តន៍សេចក្ដីណែនាំ:<br>-ណែនាំមន្ទីរពាក់ព័ន្ធ<br>-មន្ត្រីសំរបសំរួលនៃ EXCOM<br>-សហការជាមួយអង្គការជាតិ និងអន្តរជាតិ | | | | | | | | | | | | |
| ៣ | ពិភាក្សា និងរៀបចំផែនការសកម្មភាព និងថវិកា | | | | | | | | | | | | |
| ៤ | ផ្ដល់របាយការណ៍ និងអនុសាសន៍ និងបូកសរុបការងារប្រចាំឆ្នាំមកក្រសួង | | | | | | | | | | | | |
| **ថ្នាក់ស្រុក** | | | | | | | | | | | | | |
| ១ | អនុវត្តសេចក្ដីណែនាំ:<br>-ផ្សព្វផ្សាយដល់ការិយាល័យពាក់ព័ន្ធ អ្នកសំរបសំរួលថ្នាក់ស្រុក អង្គការសមាគមនៅ ក្នុងមូលដ្ឋាន<br>-សហការជាមួយមន្ត្រីសំរបសំរួលស្រុក និងអង្គការពាក់ព័ន្ធដើម្បីណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ | | | | | | | | | | | | |
| ២ | -រៀបចំផែនការសកម្មភាព ផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំ សង្កាត់<br>-ចូលរួមក្នុងការរៀបចំធ្វើសមាហរណកម្មស្រុក | | | | | | | | | | | | |
| ៣ | -តាមដានវាយតំលៃការអនុវត្តន៍<br>-រៀបចំរបាយការណ៍ជូនមន្ទីរ | | | | | | | | | | | | |
| **ថ្នាក់ឃុំ** | | | | | | | | | | | | | |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |

# Detailed Guideline on Support of Social Affairs, Labour, Vocational Training and Youth Rehabilitation Sectors to Commune/Sangkat Councils

----------------

## I- General Situation:

### *A. Poverty Context:*

According to the Socio-Economic Survey in 1998, it shows that 36% of population are living under the poverty line and 85% of those in rural area. Tendency of land loss is reliable indicator to show the direction toward poverty. Poverty is caused by lack of opportunity in agriculture and economic activities and other activities in rural areas. Lack of opportunities caused by many factors affected the capacity to get access and balance of public service delivery.

We have many policies to focus on those complications. The government strategy is to reduce poverty through high sustainable economic growth in long-term by ensuring sustainable environment and social clarity. So effort is taken into account to settle poverty by focusing on the establishment of simplified context for economic growth. Appropriate macro-economic and finance sectors are important, but they still cannot ensure better living condition of the most poor in rural areas. The national poverty reduction strategy defines threatening factors and policy programme with direction for income generation for people living in rural areas. The improvement of all sectors will respectively contribute to poverty reduction by improving access to utilisation of basic services. Living condition of rural people is better relies on dimension of poverty reduction decrease. Poor health, lack of education, lack of infrastructure and low productivity will make people living in rural areas fall in poverty.

According tc e Socio-Economic Survey in 1998, Cambodia has much changed in poverty reduction. The rate of people living under poverty line decreased from 40% to 36% and this rate will decrease to 31% by 2005. Most of the economic growth resulted from investment in industry and services. Even only 36% under poverty line, but the rate of almost close living security food line is 20%. Most of them are farming in rural areas. Remarkably, they are farming with traditional methods, not modern agricultural techniques. Poor living condition pushes them to move to urban areas to look for jobs and increase their income as commercial enterprise workers, construction workers, porters, tri-cycle runners, motor-taxi drivers, etc based on their capacity. Due to their limited skills or skills not responding to the labour market, it makes them street people in urban areas, unemployed, staying in the street, public garden and easy to be vulnerable in conflict with the laws in society. Replacement comprises of diversity of people such as beggars, gangsters, robbers, thieves, prostitutes, drug users, crime, etc.

The war and poverty remained many people living in miserable and famine condition. After the war, Cambodian people are living in peace throughout the country, but poverty still threatens people's lives especially people living in rural areas about 84.3 percent.

Within the above context, the ministry developed a strategy of framework for implementing the pilot project on support of social affairs, labour, vocational training and youth rehabilitation to Commune/Sangkat Councils for alleviating people's poverty by mainstreaming social affairs, labour, vocational training and youth rehabilitation, based on decentralisation and deconcentration system by collaborating with Seila programme.

## II- General Mission:

The Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation (MOSALVY), is mandated by the Royal Government of Cambodia to govern and manage all activities related to the fields of social affairs, labour, vocational training and youth rehabilitation. Up to the end of 2002, the Ministry employs 1,711 civil servants including 648 working at central administration, 1,063 working at local administration and 423 contract staff.

### 1. Roles and Responsibilities:

The Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation fulfils the roles and responsibilities as follows:

#### A. Social Affairs Sector:

- Facilitate and manage all government social services for assisting people by taking actions against any disasters and prepare social activities to help vulnerable people , namely the elderly without support, people with disability, street children, orphans, street people, drug abused children, prostitutes, people affected by HIV/AIDS, etc.
- Assist people in most difficult circumstance in society;
- Collaborate with concerned institutions to take legal actions to control and prevent prostitution and human trafficking;
- Assist victims of catastrophes, such as natural disaster, wars and others;
- Support, care for, protect and educate all kinds of orphans;
- Protect children who are victims of sexual abuse and other forms of trafficking and exploitation;

- Prepare policy on support for people with disability and facilita physical rehabilitation and provide vocational skills to all kinds of people with disability;
- Manage pension scheme for civil servants defined by the law on common status of civil servants of the Kingdom of Cambodia;
- Manage social insurance allowance for children orphaned with their dead civil servants.

*B- Labour Sector:*

- Implement the labour code to improve sanitation, health, security and work condition in factories and enterprises;
- Inspect factories and enterprises as defined by the provision on employment administration;
- Follow up the implementation of labour code and provisions involved in employment norms, conditions and sanitation, and the protection of the health of workers/employees;
- Help protect and coordinate the communication between NGO's representing workers/employees and employers' associations in factories and enterprises;
- Settle individual and joint work disputes based on the laws;
- Study and prepare national policies for employment to assess labour market requirement, the number of the unemployed and underemployed workers;
- Manage the uses of Cambodian labour forces locally and abroad;
- Prepare services of social security for those who are under the provisions of labour code and manage national cash box for social security.

*C- Vocational Training Sector:*

- Develop national policy for employment based on vocational training policy, help develop skills and direct workers/employees who are in the most difficult

circumstances to find appropriate jobs and skills and help enterprises get qualified manual workers;

- Organise and manage vocational training school linked with labour market;
- Collaborate and coordinate with NGOs and IOs to develop vocational training sector;
- Collaborate with factories and enterprises to promote and develop vocational skills;
- Manage apprentice work and cash box of apprentice training as defined by Labour Code;

### *D- Youth Rehabilitation Sector:*

- Manage children between 7 and 18 years old, committing offenses, evil acts, debauchery, drug by giving them rehabilitation programme in order to convert them into good citizen;
- Establish rehabilitation centres for educating and providing vocational training to juvenile delinquents;
- Collaborate with involved ministries and institutions and NGOs to develop training curriculum and rehabilitation programme for juvenile delinquents;
- Develop guidelines, laws and norms related to the management of youth rehabilitation.

## *2. Problems Faced:*

According to the field visit for assessment, the implementation of Seila programme in some provinces/municipalities has faced some problems, such as:

- Social affairs, labour, vocational training and youth rehabilitation sectors is very wide dimension;
- The ministry has not had any clear guideline for supporting social affairs, labour, vocational training and youth rehabilitation sectors to CC from national to local level;
- Dissemination of roles and responsibilities of social affairs, labour, vocational training and youth rehabilitation sectors is limited at local level;

- Capacity building of local staff is limited;
- Collaboration between DSALVY and OSALVY and PRDC is limited;
- The Ministry has no structure at commune/sangkat level;
- Yet social affairs integrated into the development plan of commune/sangkat;
- Limited local communication system;
- Common understanding in social affairs of the people is limited.

## 3. *Vision:*

The vision of mainstream of social affairs, labour, vocational training and youth rehabilitation into the development plan of commune/sangkat will be defined by key factors; such as access to resources, effectiveness, transparency and capacity of management of local people. We expect that, the mainstream of social affairs, labour, vocational training and youth rehabilitation into the development plan of commune/sangkat is to contribute importantly to people's poverty reduction through good participatory governance for providing supporting services to CC with effectiveness and sustaining partnership between the RGC, civil society and private sectors.

## 4. *Objective:*

With the objective to promote social affairs, labour, vocational training and youth rehabilitation support to CC and implement the pilot programme of decentralisation and deconcentration system by collaborating with Seila programme, contributing to the people's poverty reduction, it is necessary to support activities as follows:

- Provide services to the elderly without support, disabled people, orphans, street children, drug children, juvenile delinquents;

- Provide services to street people, prostitutes, people living ' 'h HIV/AIDS and prevent human trafficking by prevenung at local level;
- Protect child victim of sexual abuse and of any forms of exploitation;
- Educate and prevent domestic violence, especially in rural areas;
- Promote wellbeing of people living in rural areas by cooperating with concerned institution and organisations;
- Promote balance of gender in society, especially in rural areas;
- Assist victims of any disasters, natural disaster, wars and other incidences;
- Resettle labour disputes;
- Provide vocational training for increasing job placement appropriate to real situation and labour market requirement.

Based on the Law on Administration and Management of CC, dated January 15, 2001 in article 40, clearly defined the roles and responsibilities of the second deputy of commune chief in social affairs, the support to CC and based on above vision, DSALVY shall implement roles and responsibilities as describes in third section.

## *III. Guiding for supporting SALVY Sectors to CC:*

### *1. Local Participation:*

In order to achieve the guideline implementation to mainstream social affairs and develop commune/sangkat, it is necessary to collaborate with concerned institutions and be directly supported by local people:

- Be supported by local people;
- Some contributions to programme implementation;
- DSALVY and OSALVY collaborate with Seila programme and their provincial and district facilitation staff to implement the support CC related to

mainstreaming of social affairs into the development plan c ommune/sangkat.

## 2. *Framework and Roles in Implementation:*

To ensure effective management of social affairs, labour, vocational training and youth rehabilitation sectors and contribute to capacity building of local authority and a part of implementation of the policy of decentralisation and deconcentration. The approach of piloting implementation of the guideline on the support of social affairs, labour, vocational training and youth rehabilitation sectors to commune/sangkat requires facilitation at all levels in discussion and agreement with concerned agencies in the implementation of this guideline.

### A. *Roles and Responsibilities of DOSALVY:*

- Disseminate roles and responsibilities of social affairs, labour, vocational training and youth rehabilitation to local people for mainstreaming these issues into Seila programme;
- Cooperate with the provincial development committee and the Provincial Planning Department to prepare workplan, responding to the priority for supporting CC;
- Cooperate with Provincial ExCom to request for budget package for developing their own field;
- Adjust and provide recommendations on social affairs development at local level;
- Prepare networking at provincial, district/Khan and commune/sangkat levels;
- Cooperate with IOs and NGOs to provide support services to CC;
- Follow up, monitor, evaluate and readjust;
- Provide regular activities report to MoSALVY.

## B. Roles and Responsibilities of OSALVY:

- Guide CC how to collect data on social affairs, labour, vocational training and youth rehabilitation work;
- Collect information on vulnerable people in district/khan, including families in difficult circumstance, street people, street children, juvenile delinquencies, elderly people without support, orphans, prostitutes, people with disability, etc.
- Collaborate with IOs, NGOs in service delivery to support CC;
- Disseminate guideline from national to local level to CC;
- Collect information about labour market and unemployment and disseminate for the unemployed. Study the requirement of vocational training appropriate to local labour market
- Cooperate with district development committee and relevant offices to disseminate guideline on social affairs, labour, vocational training and youth rehabilitation to CC;
- Prepare draft workplan for supporting social affairs, labour, vocational training and youth rehabilitation sectors in their own districts/khans based on the 11 steps of commune development planning process.
- Collaborate with CC in:
    - Collect information of vulnerable people
    - Identify local real need on social issues
    - Prepare commune/sangkat development plan
- Follow up, monitor, evaluate and adjust social affairs work
- Provide regular activities report to DSALVY.

## IV. Expected Output:

Based on above guideline, the MoSALVY expects to achieve the outputs as follows:

- CC and local people will understand the sectors of soci affairs, labour, vocational training and youth rehabilitation;
- Ensure sustainable collaboration between CC and concerned institutions;
- Contribute to the people's poverty reduction;
- Better social services will be strengthened and expanded at local level;
- Minimise unemployment rate;
- Vulnerable people will be delivered social services;
- Wellbeing of local people is promoted;
- People will have vocational skills and employment appropriate to the real situation.

### *V. Activities:*

### *1. Workplan:*

| No | Activities | ·onths | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| National Level | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| 1 | Develop guideline and regulations | | | | | | | | | | | | |
| 2 | Disseminate guideline and regulations | | | | | | | | | | | | |
| 3 | Monitoring, evaluation and adjustment | | | | | | | | | | | | |
| Provincial level | | | | | | | | | | | | | |
| 1 | Disseminate continuing guideline and regulations | | | | | | | | | | | | |
| 2 | Facilitate and follow up the implementation of guideline:<br>- Guide concerned departments<br>- Facilitators of ExCom<br>- Cooperate with national and international organisations | | | | | | | | | | | | |
| 3 | Discuss and develop budget and workplan | | | | | | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 4 | Provide report and recommendations and recapitulate annual work and submit to the Ministry | | | | | | | | | | | | |
| District level | | | | | | | | | | | | | |
| 1 | Implement the guideline:<br>- Disseminate to concerned offices, district facilitators, organisations, associations at local level<br>- Cooperate with district facilitators and relevant organisations in the guiding of CC | | | | | | | | | | | | |
| 2 | - Develop workplan based on development plan of CC<br>- Participate in the district integration<br>- Follow up and evaluate the implementation<br>- Make report to DSALVY | | | | | | | | | | | | |
| **Commune level** | | | | | | | | | | | | | |
| 1 | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | |

អង្គការលេខក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

